ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ : ០៥ ប្រក៣

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី
# ថ្ងៃសុក្រ ៩កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦
# ត្រូវនឹងថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣

នៅព្រឹកថ្ងៃសុក្រ ៩កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង៨និង១៥នាទីព្រឹក នៅវិមានសន្តិភាព ទីស្តីការគណៈរដ្ឋមន្ត្រី មានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យនិងពិភាក្សាលើ៖

១- សេចក្តីព្រាងក្រមបរិស្ថាននិងធនធានធម្មជាតិ។

២- បញ្ហាផ្សេងៗ៖ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិលើ សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មសេវាកម្មអាស៊ាន។

ក្រោយពីបានស្តាប់របាយការណ៍ សម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបានធ្វើការពិភាក្សាផ្លាស់ប្តូរយោបល់ និងសម្រេចតាមរបៀបវារៈ ដែលមានលទ្ធផលនិងខ្លឹមសារសង្ខេបដូចខាងក្រោម៖

## ១- សេចក្តីព្រាងក្រមបរិស្ថាននិងធនធានធម្មជាតិ

ចាប់តាំងពីការបង្កើតរដ្ឋលេខាធិការដ្ឋានគ្រប់គ្រងបរិដ្ឋាន នៅឆ្នាំ១៩៩៣ និងបានក្លាយជាក្រសួងបរិស្ថាននៅឆ្នាំ១៩៩៦ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានចង្អុលបង្ហាញផ្លូវនិងតម្រង់ទិសប្រកបដោយចក្ខុវិស័យវែងឆ្ងាយ ដែលបានធ្វើឱ្យកម្ពុជាឈានជើងយ៉ាងស្វាហាប់ឆ្លងចូលទំព័រសករាជថ្មីដែលមិនធ្លាប់មានក្នុងប្រវត្តិសាស្ត្រលើមាគ៌ាអភិវឌ្ឍន៍ប្រកបដោយចីរភាពនិងបរិយាបន្នសង្គម ដោយក្នុងនោះកម្ពុជាសម្រេចបានសមិទ្ធផលសំខាន់ៗជាច្រើន និងត្រូវបានសហគមន៍អន្តរជាតិទទួលស្គាល់ថាជាជើងឯកមួយនៅក្នុងកិច្ចការបរិស្ថាន ដើរទាន់និន្នាការវិវឌ្ឍរបស់មនុស្សលោក និងការទទួលខុសត្រូវរួម ដែលបានឈានដល់ការអនុម័តដោយស្ថាប័ននីតិប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា លើអនុសញ្ញារីយ៉ូសំខាន់៣ គឺអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ អនុសញ្ញាស្តីពីជីវៈចម្រុះ និងអនុសញ្ញាសហប្រជាជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងវាលរហោស្ថានកម្ម។

ស្របតាមដំណើរឈានឡើងយ៉ាងស្វាហាប់របស់កម្ពុជា និងដើម្បីឆ្លើយតបទៅនឹងតម្រូវការជាយុទ្ធសាស្ត្រក្នុងការដោះស្រាយបញ្ហាប្រឈមនានា នាពេលបច្ចុប្បន្ននិងទៅអនាគត ព្រមទាំងដើម្បីឆ្លើយតបទៅនឹងអាទិភាពសង្គម សេដ្ឋកិច្ច វប្បធម៌ សន្តិសុខនយោបាយ និងបរិស្ថានកម្ពុជា ក៏ដូចជានិន្នាការសកល ក្រសួងបរិស្ថាននិងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព បានធ្វើការពិនិត្យឡើងវិញនិងបានធ្វើបច្ចុប្បន្នភាពសម្រួចបន្ថែមនូវក្របខ័ណ្ឌច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តនានា ក៏ដូចជាបានតាក់តែងនូវ «សេចក្តីព្រាងសៀវភៅសស្តីពីបរិស្ថាន និងការអភិវឌ្ឍដោយចីរភាព» និង «សេចក្តីព្រាងក្រមបរិស្ថាននិងធនធានធម្មជាតិ» នេះជាដើម។

សេចក្តីព្រាងក្រមបរិស្ថាននិងធនធានធម្មជាតិ ត្រូវបានរៀបចំឡើងក្នុងគោលបំណងប្រមូលផ្តុំ សំយោគបញ្ចូលគ្នានូវបទប្បញ្ញត្តិច្បាប់និងលិខិតបទដ្ឋាននានាជាធរមានពាក់ព័ន្ធនឹងវិស័យបរិស្ថាន និងធនធានធម្មជាតិ ដោយធ្វើសមាហរណកម្ម សុខដុមនីយកម្ម និងទំនើបកម្ម ឱ្យមានភាពជាក់ស្តែងនិយម សង្គតិភាព និងវិសាលភាពទូលំទូលាយគ្រប់ជ្រុងជ្រោយ ដើម្បីក្លាយជាបទប្បញ្ញត្តិគោលដែលកំណត់ពីដែនសមត្ថកិច្ចនៃក្រសួងស្ថាប័នពាក់ព័ន្ធ សំដៅសម្រួលដល់ការអនុវត្តមុខងារ និងតួនាទីភារកិច្ចរៀងៗខ្លួន ក្នុងស្មារតីឯកភាពជាតិ ស្របទៅនឹងបរិបទនៃការរីកចម្រើនរបស់សង្គម។ សេចក្តីព្រាងក្រមនេះ បំពេញបន្ថែមនិងមានភាពស៊ីសង្វាក់ប្រទាក់ក្រឡាគ្នាជាមួយនឹងច្បាប់និងលិខិតបទដ្ឋានពាក់ព័ន្ធជាធរមាន មានជាអាទិ៍ ក្រមព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ ច្បាប់ភូមិបាល ច្បាប់ស្តីពីទេសចរណ៍ ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក ក្នុងគោលដៅបន្តជំរុញដំណើរការអភិវឌ្ឍប្រទេសជាតិនិងការពង្រឹងនីតិរដ្ឋ ទៅកាន់ជំណាក់កាលថ្មីនៅលើមាគ៌ាអភិវឌ្ឍន៍បៃតងនិងប្រកបដោយចីរភាព តាមការចង្អុលបង្ហាញផ្លូវប្រកបដោយគតិបណ្ឌិតនិងចក្ខុវិស័យវែងឆ្ងាយរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី។

សេចក្តីព្រាងក្រមបរិស្ថាននិងធនធានធម្មជាតិ ត្រូវបានតាក់តែងឡើងដោយផ្អែកលើគោលការណ៍សំខាន់ចំនួនបីគឺៈ ទី១. លិខិតបទដ្ឋានគតិយុត្តក្នុងវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវបានធ្វើសមាហរណកម្ម, ទី២. លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវបានធ្វើសុខដុមនីយកម្ម, និង ទី៣. លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា ត្រូវបានធ្វើទំនើបកម្មឱ្យឆ្លើយតបនឹងនិន្នាការវិវឌ្ឍនៃសង្គម។ តាមរយៈសេចក្តីព្រាងក្រមបរិស្ថាននិងធនធានធម្មជាតិនេះ នឹងផ្តល់នូវគុណប្រយោជន៍ចម្បងៗមួយចំនួន ដូចជាៈ (១) ពង្រឹងនិងធ្វើឱ្យប្រសើរឡើងបន្ថែមទៀតលើការគ្រប់គ្រងបរិស្ថាន កិច្ចគាំពារ ការអភិរក្ស និងការស្តារឡើងវិញនូវធនធានធម្មជាតិ ជីវៈចម្រុះ មុខងារប្រព័ន្ធអេកូឡូស៊ី និងការរស់នៅប្រកបដោយចីរភាព, (២) កំណត់ទិសដៅរួមជាយុទ្ធសាស្ត្រ សម្រាប់កិច្ចគាំពារបរិស្ថាននិងការអភិរក្សធនធានធម្មជាតិ, (៣) ពង្រីកលទ្ធភាពយ៉ាងទូលំទូលាយដល់បណ្តាក្រសួង ស្ថាប័ន និងមជ្ឈដ្ឋានទាំងអស់ ក្នុងការចូលរួមកាន់តែប្រសើរជាងមុននៅក្នុងកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងនិងអភិរក្សធនធានធម្មជាតិនិងជីវៈចម្រុះ, (៤) បង្កើនប្រសិទ្ធភាពនិងប្រសិទ្ធផលនៃការអនុវត្តបេសកកម្មគ្រប់គ្រង ការពារ អភិរក្ស និងស្តារឡើងវិញនូវធនធានធម្មជាតិ ជីវៈចម្រុះ បេតិកភណ្ឌធម្មជាតិនិងវប្បធម៌ សំដៅធានាបាននូវការអភិវឌ្ឍប្រកបដោយចីរភាព និងការចូលរួមថែរក្សានូវភាពរុងរឿងសម្រាប់ពលរដ្ឋកម្ពុជាគ្រប់ជំនាន់, (៥) ផ្តល់យន្តការជំរុញនិងលើកកម្ពស់ការយល់ដឹងនិងការស្រាវជ្រាវអំពីបរិស្ថាន ដល់គ្រប់មជ្ឈដ្ឋានសង្គមទាំងអស់, និង (៦) ដើរតួជាបទប្បញ្ញត្តិគោលមួយដ៏រឹងមាំសម្រាប់មន្ត្រីអនុវត្តច្បាប់ ជាពិសេសមន្ត្រីដែលមានសមត្ថកិច្ចពាក់ព័ន្ធនឹងការបង្ក្រាបបទល្មើសបរិស្ថាននិងធនធានធម្មជាតិ ក៏ដូចជាមន្ត្រីអនុវត្តច្បាប់នៃក្រសួង ស្ថាប័ន ឬអង្គភាពពាក់ព័ន្ធទាំងអស់។

សេចក្តីព្រាងក្រមបរិស្ថាននិងធនធានធម្មជាតិ ត្រូវបានរៀបចំជា១២គន្ថី និង៨៦៥មាត្រា ហើយត្រូវបានសម្រេចឯកភាពដោយអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។

## ២- បញ្ហាផ្សេងៗ

កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានសម្រេចបញ្ជូន «សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មសេវាកម្មអាស៊ាន» ទៅសុំការអនុម័តយល់ព្រមពីស្ថាប័ននីតិប្បញ្ញត្តិ។

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានមានប្រសាសន៍ថា៖

- រាជរដ្ឋាភិបាល ថ្លែងអំណរគុណនិងកោតសរសើរខ្ពស់ដល់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងក្រុមគ្រូពេទ្យ ដែលបានសហការរៀបចំកម្មវិធីកម្សាន្តនានា ព្រមទាំងខិតខំធានាការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈបានល្អប្រសើរក្នុងឱកាសពិធីចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ គ.ស.២០២៣ កន្លងទៅ ក៏ដូចជាការរៀបចំព្រឹត្តិការណ៍អង្គរសង្ក្រាន្ត នៅខេត្តសៀមរាប បានប្រព្រឹត្តទៅដោយរលូននិងជោគជ័យ ប្រកបដោយភាពសប្បាយរីករាយនិងសាមគ្គីជាតិ ក្រោមម្លប់នៃសន្តិភាព

- ក្នុងនាមជាម្ចាស់ផ្ទះនៃព្រឹត្តិការណ៍កីឡាស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ឆ្នាំ២០២៣នេះ រាជរដ្ឋាភិបាលកម្ពុជាត្រៀមខ្លួនរួចជាស្រេចក្នុងការទទួលបដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅចំពោះក្រុមអត្តពលិកនិងប្រតិភូកីឡារបស់បណ្តាប្រទេសដែលចូលរួមក្នុងព្រឹត្តិការណ៍កីឡាខាងលើនេះ ព្រមទាំងរៀបចំការប្រកួតឱ្យប្រព្រឹត្តទៅដោយរលូន អធិកអធម និងទទួលបានភាពរីករាយជាអតិបរមា ដើម្បីរឹតចំណងសាមគ្គីភាពនិងមិត្តភាពរវាងបណ្តាប្រទេសសមាជិកអាស៊ានទាំងអស់

- រាជរដ្ឋាភិបាល ប្រកាសលើកលែងការបង់ថ្លៃសិទ្ធិចូលរួមប្រកួតរបស់អត្តពលិកទាំងអស់ និងផ្តល់ការស្នាក់នៅ ហូបចុក និងដឹកជញ្ជូន ដោយឥតគិតថ្លៃចំពោះអត្តពលិក គ្រូបង្វឹក និងប្រតិភូកីឡាក្នុងព្រឹត្តិការណ៍កីឡាស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ឆ្នាំ២០២៣នេះ

- រាជរដ្ឋាភិបាល ប្រកាសផ្តល់សំបុត្រចូលរួមទស្សនាព្រឹត្តិការណ៍កីឡាស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ឆ្នាំ២០២៣នេះ ដោយមិនគិតថ្លៃ ជូនដល់ក្រុមអ្នកគាំទ្រអត្តពលិកនៃបណ្តាប្រទេសដែលចូលរួមប្រកួត ដោយកំណត់ចំនួនជាក់លាក់ និងប្រគល់តាមរយៈប្រតិភូកីឡាដែលតំណាងឱ្យប្រទេសនីមួយៗ

- រដ្ឋបាលរាជធានី ខេត្ត ទូទាំងប្រទេស ត្រូវយកចិត្តទុកដាក់បង្កលក្ខណៈងាយស្រួលជូនប្រជាពលរដ្ឋអាចទស្សនាការប្រកួតកីឡាស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ឆ្នាំ២០២៣នេះ បានដោយសេរី ដោយត្រូវរៀបចំការផ្សាយបន្តផ្ទាល់ការប្រកួត នៅតាមបណ្តាទីតាំងសមរម្យក្នុងមូលដ្ឋានរបស់ខ្លួន ព្រមទាំងត្រូវធានាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈឱ្យបានល្អប្រសើរ

- រាជរដ្ឋាភិបាល នឹងរៀបចំពិធីជួបសំណេះសំណាលជាមួយក្រុមអត្តពលិកនិងប្រតិភូកីឡាកម្ពុជា នៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៣ ដើម្បីលើកទឹកចិត្តនិងជូនពរដល់ក្រុមអត្តពលិកនិងប្រតិភូកីឡាកម្ពុជា ឱ្យទទួលបានជោគជ័យដណ្តើមមេដាយឱ្យបានច្រើនជាអតិបរមា ក្នុងការប្រកួតកីឡាស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ឆ្នាំ២០២៣នេះ

- រាជរដ្ឋាភិបាល យកចិត្តទុកដាក់ការពារបរិស្ថាននិងធនធានធម្មជាតិយ៉ាងម៉ត់ចត់ និងប្រកាន់ជំហរច្បាស់លាស់ ដោយមិនបណ្តោយឱ្យប្រទេសកម្ពុជាក្លាយជាទីតាំងចាក់សំរាមរបស់ប្រទេសណាមួយឡើយ

- រាជរដ្ឋាភិបាល ណែនាំឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលខេត្តនៅជុំវិញបឹងទន្លេសាបសិក្សាស្រាវជ្រាវនិងពិនិត្យលទ្ធភាពក្នុងការសាងសង់ទ្វារទឹកផ្នែកណាមួយនៅបឹងទន្លេសាប ដើម្បីតម្កល់ទឹកទុកក្នុងបឹងទន្លេសាបកុំឱ្យទឹកហូរចេញលឿនពេក ដោយត្រូវសិក្សាអំពីផលប៉ះពាល់ផ្សេងៗលើទិដ្ឋភាពច្បាប់ បរិស្ថាន ដីធ្លី និងការបង្កបង្កើនផលរបស់ប្រជាពលរដ្ឋ។

កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង១០និង៣០នាទី។

ថ្ងៃសុក្រ ៩កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣